THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី 11 ខែ កញ្ញា ឆ្នាំ 2024

ខ្ញុំពិតជារំភើបចិត្តក្នុងការប្រកាសថា **វិធីជ្រើសរើសសាលា *Find Your Fit* របស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា សម្រាប់ឆ្នាំសិក្សា 2025-2026 នឹងបើកនៅថ្ងៃ សុក្រ ទី 13 ខែ កញ្ញា ឆ្នាំ 2024 វេលាម៉ោង 4:00 រសៀល។** វិធីជ្រើសរើសសាលា *Find Your Fit* អនុញ្ញាតឱ្យសិស្សដែលកំពុងសិក្សាថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 11 នាបច្ចុប្បន្ននេះ ដាក់ពាក្យសុំចូលរៀននៅសាលាណាមួយរបស់ក្រសួងអប់រំ ដែលមានកន្លែងទំនេរ នៅក្រៅតំបន់ ឬតំបន់ដែលសិស្សមិនអាចចុះឈ្មោះ សម្រាប់ឆ្នាំសិក្សាខាងមុខ។ **លិខិតដាក់ពាក្យនឹងបិទនៅថ្ងៃទី 23 ខែ តុលា ឆ្នាំ 2024 វេលាម៉ោង 11:59 យប់។**

ដូចដែលយើងបានចែករំលែកកាលពីខែមុន មានការផ្លាស់ប្តូរសំខាន់ៗមួយចំនួនចំពោះវិធីជ្រើសរើសសាលា ដែលក្រសួងអប់រំបានរៀបចំឱ្យបានល្អប្រសើរជាងមុន តាមចំណូលចិត្តរបស់សិស្ស ផ្តល់ការផ្តល់ជូនដល់សិស្សឱ្យកាន់តែច្រើនពីដំបូង សម្រួលដល់ការទទួលយកសិស្សឱ្យកាន់តែច្រើនក្នុងរយៈពេលដ៏ខ្លី ហើយនាំឱ្យមានការកាត់បន្ថយពេលវេលាដើម្បីបំពេញកន្លែងទំនេរទូទាំងសាលារបស់យើង។ យើងក៏បានប្រតិបត្តិប្រព័ន្ធជ្រើសរើសសាលារៀនថ្មី តាមការសហការជាមួយក្រុមហ៊ុនផ្តល់សេវាបច្ចេកវិទ្យារបស់យើង ដែលមានឈ្មោះថា *Avela* ដែលនឹងជួយរៀបចំ និងសម្រួលវិធីដាក់ពាក្យសុំចូលរៀន។ ខ្ញុំសូមជំរុញចិត្តសិស្សានុសិស្ស និងក្រុមគ្រួសារទាំងអស់ដែលគ្រោងនឹងចូលរួមក្នុងការជ្រើសរើសសាលាឱ្យពិនិត្យមើល ការកែសម្រួលថ្មីៗ និងការផ្លាស់ប្តូរទាំងនេះ these updates and changes មុនពេលដាក់ពាក្យស្នើសុំ។

បន្ថែមពីលើការផ្លាស់ប្តូរទាំងនេះ និងប្រព័ន្ធថ្មីរបស់យើង យើងក៏បានរៀបចំផែនការសម្រាប់សកម្មភាពផ្សេងៗ និងបង្កើតធនធានដ៏មានប្រយោជន៍ដើម្បីជួយលោកអ្នកក្នុងវិធីជ្រើសរើសសាលា *Find Your Fit*៖

**<u>ស្វែងយល់បន្ថែមអំពីការជ្រើសរើសសាលា៖</u>**

- **សិក្ខាសាលាអំពីការផ្តល់ជំនួយដល់ការដាក់ពាក្យស្នើសុំ៖** ក្រុមផ្តល់ជំនួយដល់ការជ្រើសរើសាលា *Find Your Fit* ផ្តល់ជូននូវសិក្ខាសាលាអំពីការផ្តល់ជំនួយដល់ការដាក់ពាក្យស្នើសុំ នៅតាមសាលានានាទូទាំងទីក្រុង សម្រាប់ក្រុមគ្រួសារក្នុងអំឡុងពេលដាក់ពាក្យស្នើសុំ។ សូមចូលទៅកាន់ គេហទំព័រជ្រើសរើសសាលា school selection website សម្រាប់ម៉ោង និងទីតាំងនៃសិក្ខាសាលានាពេលខាងមុខ។
- **ការណែនាំពីរបៀប (How-To-Guides)**៖ ការណែនាំពីរបៀប គឺជាឯកសារដែលណែនាំមួយជំហានម្តងៗ ពិពណ៌នាអំពីសកម្មភាពផ្សេងៗដែលក្រុមគ្រួសារនឹងត្រូវធ្វើនៅពេលបំពេញលិខិតដាក់ពាក្យស្នើសុំតាមអ៊ិនធ័រណិត។ ការណែនាំអាចឃើញ នៅទីនេះ here ជាមួយនឹងការបកប្រែភាសាដែលនឹងបកប្រែជូនក្នុងពេលឆាប់ៗនេះ។
- **កិច្ចប្រជុំអំពីការជ្រើសរើសសាលា**៖ មើល ការថតទុកនៃកិច្ចប្រជុំ town hall recordings ដើម្បីស្វែងយល់បន្ថែមអំពីវិធីជ្រើសរើសសាលា និងវិធីដាក់ពាក្យទាំងស្រុង។

**<u>ស្វែងយល់បន្ថែមអំពីវិទ្យាល័យដែលទទួលសិស្សផ្អែកលើលក្ខណៈវិនិច្ឆ័យ៖</u>**

- **ឧបករណ៍សម្រាប់ការស្វែងរកសាលាថ្មី៖** ឧបករណ៍ថ្មីសម្រាប់ការស្វែងរកសាលាដែលងាយស្រួលប្រើរបស់យើង ហៅថា Explore *(រុករក)* ផ្តល់ព័ត៌មានយ៉ាងទូលំទូលាយអំពីសាលានីមួយៗ។
- **ការដើរមើលវិទ្យាល័យដែលទទួលសិស្សផ្អែកលើលក្ខណៈវិនិច្ឆ័យ៖** ទៅកាន់សាលាដោយផ្ទាល់ និងមើលតាមអ៊ិនធ័រណិត ជួបជាមួយបុគ្គលិក និងស្វែងយល់បន្ថែមអំពីការអប់រំរបស់សាលា។ សូមមើលបញ្ជីសម្រាប់ថ្ងៃដើរមើលសាលានាពេលខាងមុខ នៅទីនេះ here។
- **ពិព័រណ៍សាលាក្នុងទីក្រុងហ្វីឡា (Philly School Fair)៖** ពិព័រណ៍សាលាក្នុងទីក្រុងហ្វីឡា សម្រាប់ថ្នាក់មត្តេយ្យ ដល់ទី 12 ឆ្នាំ 2024 គឺជាឱកាសមួយសម្រាប់សិស្សានុសិស្ស និងក្រុមគ្រួសារប្រាស្រ័យទាក់ទងជាមួយសាលា និងកម្មវិធីដែលមាននៅក្នុងទីក្រុង សួរសំណួរ និងស្វែងយល់អំពីតម្រូវការនៃការដាក់ពាក្យ និងពេលកំណត់។ ពិព័រណ៍នេះមានអ្វីៗជាច្រើនសម្រាប់វិទ្យាល័យសាធារណៈ វិទ្យាល័យសាលាឆាធ័រ និងវិទ្យាល័យសាលាឯកជន ដើម្បីបង្ហាញសម្ភារៈផ្សព្វផ្សាយ វីដេអូ ព័ត៌មានទំនាក់ទំនង និងបង្ហោះព្រឹត្តិការណ៍ដែលដឹកនាំដោយសាលាតាមអ៊ិនធ័រណិត។ ស្វែងយល់បន្ថែមអំពីពិព័រណ៍ នៅទីនេះ here។
- បញ្ជីរាយឈ្មោះវិទ្យាល័យ ឆ្នាំ 2025-2026៖ បញ្ជីរាយឈ្មោះវិទ្យាល័យ ឆ្នាំ 2025-2026 2025-2026 High School Directory ក៏មានដែរ ដែលផ្តល់បញ្ជីពេញលេញអំពីកម្មវិធី និងបទពិសោធន៍របស់វិទ្យាល័យផ្សេងៗនៅក្នុងក្រសួងអប់រំរបស់យើង និងទីតាំងរបស់វិទ្យាល័យ។ សិស្សអាចស្វែងរកបញ្ជីរាយឈ្មោះដើម្បីរកមើលកម្មវិធីសិក្សា មុខវិជ្ជាសិក្សា កីឡា កម្មវិធីក្រៅម៉ោងសិក្សា និងកម្មវិធីអប់រំផ្នែកអាជីព និងបច្ចេកទេស (CTE) ដែលមាននៅវិទ្យាល័យនីមួយៗ ទូទាំងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

យើងខ្ញុំសូមអញ្ជើញលោកអ្នកឱ្យស្វែងរកចម្លើយចំពោះសំណួរបន្ថែមរបស់លោកអ្នកនៅលើគេហទំព័រជ្រើសរើសសាលា។ បន្ទាប់ពីបានមើលគេហទំព័រនេះហើយ ប្រសិនបើលោកអ្នកមិនអាចរកចម្លើយដែលលោកអ្នកត្រូវការ សូមទាក់ទងមកយើងតាមរយៈវេទិកាទំនាក់ទំនងឆ្លងឆ្លើយរបស់យើង ***Let's Talk*** ដោយចុចលើផ្ទាំង Contact Us នៅផ្នែកខាងក្រោមនៃគេហទំព័រជ្រើសរើសសាលា។ យើងខ្ញុំសុំឱ្យលោកអ្នកមានការអត់ធ្មត់ ព្រោះអីយើងខ្ញុំទទួលទូរសព្ទ និងអ៊ីមែលច្រើនជាងធម្មតា ក្នុងអំឡុងពេលនេះ។

សូមអរគុណចំពោះការជ្រើសរើស ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា សម្រាប់ការអប់រំរបស់កូនលោកអ្នក។ យើងខ្ញុំទន្ទឹងរង់ចាំដើម្បីគាំទ្រលោកអ្នក និងកូនរបស់លោកអ្នកក្នុងអំឡុងពេលនៃវិធីជ្រើសរើសសាលា *Find Your Fit* សម្រាប់ឆ្នាំសិក្សា 2025-2026។ យើងខ្ញុំប្តេជ្ញាធ្វើជាដៃគូជាមួយលោកអ្នក ដើម្បីរៀបចំពួកគេឱ្យស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេចង់បាន។

ក្នុងភាពជាដៃគូ

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា